ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃអង្គារ ៣ កើត ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក) លើកទី ៤

នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក) ដោយមានការអញ្ជើញចូលរួមពីសមាជិក ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាតំណាងក្រសួង-ស្ថាប័ន ចំនួន ១៦, សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

***"មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ"*** គឺជាយន្តការថ្មីមួយ សម្រាប់ផ្តល់ប្រភពធនធានបន្ថែមលើប្រភពធនធានដែលមានស្រាប់ ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ ដោយផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរ ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិលើកទី ៤ នេះ បានពិនិត្យ និងពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម÷

- វឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចរបស់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៣ របស់ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ,
- ពិនិត្យលើរបាយការណ៍វឌ្ឍនភាពការងាររបស់លេខាធិការដ្ឋាន ក.វ.ក ឆ្នាំ ២០១៩,
- ពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការសកម្មភាព ប្រចាំឆ្នាំ ២០២០ របស់ ក.វ.ក និង
- ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសៀវភៅថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ របស់ ក.វ.ក ។

បន្ទាប់ពីអង្គប្រជុំ បានធ្វើការពិភាក្សា និងបានអនុម័តលើរបៀបវារៈទាំង ៤ ខាងលើ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ប្រធានក្រុមប្រឹក្សាភិបាល បានធ្វើការវាយតម្លៃខ្ពស់ ចំពោះលទ្ធផលឆ្នាំ ២០១៩ និងបានដាក់ទិសដៅការងារអាទិភាពដល់លេខាធិការដ្ឋាន ក.វ.ក សម្រាប់អនុវត្តឆ្នាំ ២០២០ ខាងមុខនេះ ដូចខាងក្រោម÷

១. លេខាធិការដ្ឋាន គ.វ.ក សម្របសម្រួលជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) រៀបចំដាក់ឲ្យអនុវត្តយន្តការប្រកួតប្រជែងទទួលហិរញ្ញប្បទានសម្រាប់រដ្ឋបាលឃុំ សង្កាត់ ដោយទុកលទ្ធភាពឲ្យរដ្ឋបាលខេត្តទទួលខុស ត្រូវគ្រប់គ្រង និងអនុវត្តយន្តការនេះ,

២. លេខាធិការដ្ឋាន គ.វ.ក សម្របសម្រួលជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីអនុវត្តគម្រោងដែលទទួលហិរញ្ញប្បទានពី ADB ឲ្យបានទាន់ពេលវេលា,

៣. អនុម័តកំណត់ស្រុកគោលដៅដែលត្រូវទទួលហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងថវិការដ្ឋ និងថវិកាហិរញ្ញប្បទានពី ADB ។